00008485

LN0001022
(០១ បន្ត)
E3/216



## កំណត់ហេតុ អំពីទស្សនកិច្ច អចិន្ត្រៃយ៍

## នៅភូមិភាគពាយ័ព្យ

## ថ្ងៃ ២០-២៤ សីហា ១៩៧៥

---

### I- សេចក្តីរាយការណ៍អំពីសភាពការណ៍ទូទៅ នៅមូលដ្ឋាន

#### ១- សភាពការណ៍ប្រជាជន :

នៅគ្រប់កន្លែង បានរៀបចំឱ្យប្រជាជនមានជំរក ។ ប្រជាជនចាស់នឹងន ។ ការរស់នៅមិនទាន់ខ្វះខាត ។ បក្សបានផ្តល់ជីវភ័ណ្ឌពីក្រុងបន្តបន្ទាប់ ។ ប៉ុន្តែកន្លែងស្រុកឆ្ងាយ នៅខ្វះខាតខ្លះដែរ ។ ជំងឺឈឺថ្កាត់ក៏មានច្រើន ។

ប្រជាជនថ្មីមានការខ្វះខាត ខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង ។ ខាងសិចល្វា នឹងតាមស្ទឹងមង្គលបូរី គ្រុនក្តៅច្រើន ។

ខាងរដ្ឋអំណាចក្តាប់ប្រជាជន ជាទូទៅបាន ។ ប៉ុន្តែដោយឡែក សង្កេតឃើញថា : កន្លែងណាមានកម្មាភិបាលល្អ ស្គាល់ដឹកនាំ នឹងប្រជាជននឹងន កន្លែងណាគ្មានកម្មាភិបាល ឬស្គាល់មិននឹងន រភាក់រអួលច្រើនដែរ ។ ប្រជាជនដើររទេរទេត រហូត ។

និយាយរួមប្រជាជនភាគច្រើន កក់ក្តៅនឹងបដិវត្ត ផុសផុលក្នុងចលនាកសាងប្រទេស ចលនាបង្កបង្កើនផល ។

#### ២- សភាពការណ៍ខ្មាំង :

ក- សកម្មភាពនៅព្រំដែន : ខាងថៃ ពុំទាន់ចេញជាសកម្មភាពអ្វីទេ ។ ថ្ងៃ ១៥-១៦ ខែ ៨ មានយន្តហោះមកក្រវែល ។ ប៉ុន្តែ មានសកម្មភាពពួកអាស៊ិនតាំ ដែលថៃតាំទ្រ ។ វាបញ្ជូលគ្នាវាមក ដើម្បីរកខ្មែរវា ទាក់ទងប្រជាជន នឹងនាំប្រជាជនរត់ទៅថៃ ពិសេសតាមព្រំដែន ។ វាចូលមកពី ២ ទៅ ១០ ឬ ១៥នាក់ តែត្រូវយើងស្ទាក់ចាញ់ នឹងចាប់បានជាបន្តបន្ទាប់ ។

នៅខាងលើផ្លូវ រទេះភ្លើងពួកវៀតវាបន្លំ ចូលមកធ្វើស្រែក្នុងដីយើង ចម្ងាយ ៣ គ-ម ។ យើងកំពុងដេញកំចាត់ ។

ពួកវាធ្វើទីទួលរនាំ ព្រៃឆិតប័ណ្ណនៅភ្នំម៉ាល័យ បន្តិចបន្តួចទេ ។ ដែលវាគឺអាមេរិកចិញ្ចឹម ។

២- សកម្មភាពនៅខាងក្នុង : វាមានខ្មែរបង្កប់វា រៀបចំទាក់ទងពីកន្លែងមួយទៅកន្លែងមួយ ។ វាមានបង្កប់ក្នុងចំណោមកម្មកររទេះភ្លើង (កម្មករថ្មី) ។ វាធ្វើសង្គ្រាមចិត្តសាស្ត្រ ធ្វើវិទ្ធង្សកម្ម ។

ខាងក្នុងជួរយើង ដែលសំរិតសំរាំងមិនទាន់អស់ក៏នៅមាន ។ វាប្រើប្រាស់ពួកនេះ ឱ្យនាំប្រជាជនរត់ ។ យើងចាប់វាបានជាបន្តបន្ទាប់ ហើយកំពុងបន្តរាវរកទៀត ។

៣- សភាពការណ៍យោធាយើង :

កងទ័ពភាគ ចាត់តាំងជា ២កងពលតូច ។ ១កងនៅព្រំដែន នឹងស៊ីសូផុន ១កងទៀតនៅខាងក្រោយ ។ ១កងពលតូច ចាត់តាំងជា ១០ កងវរសេនាតូច ។ ១កងវរសេនាតូច មាន ៣៥០នាក់ ។

តំបន់នៅជិតព្រំដែន ( ត ១ - ត ៣ - ត ៥ ) រៀបចំឱ្យមាន ២វរសេនាតូច ( ពី ៥ ទៅ ៦០០នាក់ ក្នុង ១វរសេនាតូច ) ។ ១ស្រុកមាន ' អនុសេនាធំ ។ ចំណែកតំបន់ខាងក្នុង មាន ១វរសេនាតូច ។

សមាសភាពនៅមានចំនុះ នៅមានលាយទាំកូនទាហាន ( កូនសួំ ៥)។ កងនារី ក៏នៅមានដោយប្រពន្ធទាហាន ។

គោលជំហរនយោបាយ សតិអារម្មណ៍ នឹងសាមគ្គីភាព អត់មានចោទទេ ។ មានកម្មាភិបាលខ្លះ មានសីលធម៌មិនល្អ ( រឿងស្រីញី ) ។ យើងឱ្យចេញពីអង្គភាព ទៅស្រុកភូមិវិញ ។

គ្រឿងសំភារៈប្រយុទ្ធមាន អឹម១១៣ ចំនួន ១៥គ្រឿង នឹងឡានពាសដែក ៤គ្រឿង ។ កាំភ្លើងធំ ១០៥ម-ម នឹងដេសេអា មានប្រហែល ២០

00008487



ដើម ។ គ្រាប់ពីជភ័ណ្ឌមានច្រើន ។ ផ្នែកសំភារៈប្រើប្រាស់ នៅមានខ្វះខាត ដូចជាអង្រឹង មុង ។

នៅពោធិសាត់ មានបាត់តាំងកងការពារក្រុង ២០០នាក់ ( គ្រប់គ្រង និងសំអាត ) ។

៤- សភាពការណ៍សេដ្ឋកិច្ច បង្កបង្កើនផល :

ក- កសិកម្ម ដំណាំស្រូវ :

បានជំរុញទៅគ្រប់កន្លែង ។ ដីចាស់បានធ្វើទាំងអស់ កន្លែងខ្លះថែមដីទៀត ។ កន្លែងភាគច្រើន នៅបាត់ដំបង ធ្វើរួចហើយ ( ស្រែពង្រួលស្រូវស្នូង ) ។ ស្រែជាច្រើនមានប្រទាយ និងលើកភ្លឺជាកង់ៗ ។ បញ្ហាទឹកម្ចាស់ការបានមួយកំរិត ។ ប៉ុន្តែនៅពោធិសាត់ ខ្វះទឹកជាខ្លាំង ( បន្លោះពោធិសាត់ទៅស្វាយដូនកែវ ) ។ រីនៅស៊ីសុផុន និងភ្នំស្រុក ទឹកច្រើនពេក ។

កប្បាស និងក្រចៅ បានដាំជាបង្គួរហើយ កំពុងជំរុញថែម ។

ខ- ឧស្សាហកម្ម :

1%- នៅក្រុងបាត់ដំបង : រោងចក្រតម្បាញក្រចៅ រោងជាងជួសជុលម៉ាស៊ីនផ្សេងៗ ( ត្រាក់ទ័រ និងឡាន ) និងរោងជាងធ្វើខ្មៅខ្ទង់ កំពុងដំណើរការ ។ យើងធ្វើខ្មៅខ្ទង់ខ្លួនឯងបាន ១ចំនួនក្រែល កំពុងជំរុញថែម ។

រោងចក្រតម្បាញ មានកម្មករជាង ៣០០ មានកីតម្បាញ ១៩២ ធ្វើក្រណាត់បានពី ៦ ៥០០ម៉ែ ទៅ ៦ ៦០០ម៉ែ ក្នុង ៨ម៉ោង ។

រោងចក្រធ្វើបាវមានកម្មករ ៤០៣នាក់ យុវជនយើងជាង ១០០នាក់ មានម៉ាស៊ីន ៨៤ ។ ម៉ាស៊ីនមួយគ្រឿង ធ្វើបាវបាន ៥០ ក្នុង៨ម៉ោង ។ សុទ្ធតែជាម៉ាស៊ីនស្វ័យប្រវត្តិ ។

2%- នៅមង្គលបូរី : រោងចក្រជួសជុលផ្សេងៗ ប្រើកម្មករ ជាង

00008488



៣០០នាក់ ។ រោងចក្រដួសដុលត្រាក់ទ័រ មានម៉ាស៊ីនក្រឡឹង ១២ គ្រ អាចធ្វើគ្រឿងប្រដាប់បានច្រើន ។ យើងធ្វើឌីណាម៉ូ ពី ១គីឡូវ៉ាត់ ដល់ ១៥គីឡូ-វ៉ាត់បាន ។ ចុងអាគុយ ក៏ធ្វើបាន ខ្វះតែផ្លាកវាទេ ដែលត្រូវទិញពីក្រៅ ។

៣/- នៅថ្មគោល : មានរោងម៉ាស៊ីនដួសដុលត្រាក់ទ័រ ១កន្លែង ប្រើម៉ាស៊ីនក្រឡឹង ៤គ្រឿង ។ កន្លែងនេះ នៅខ្វះម៉ាស៊ីន ២គ្រឿងទៀត ពិសេសម៉ាស៊ីនសំលៀង ។

៤/- នៅអណ្ដើកហែប : ម៉ាស៊ីនថ្លិចកប្បាសកំពុងរៀបចំដួសដុល និងរៀបចំឡើងវិញ ។

*

* *

## II- មតិណែនាំ របស់អង្គការ

### ១- កិច្ចដំណើរការការពារប្រទេស :

#### ក- បញ្ហាគន្លឹះ គឺដោះស្រាយសភាពការណ៍នយោបាយរបស់ប្រជាជន :

បញ្ហាសំខាន់ គឺដោះស្រាយសភាពការណ៍នយោបាយ របស់ប្រជាជន ធ្វើយ៉ាងណាឱ្យប្រជាជននឹងន សាមគ្គីជាធ្លុងមួយ ជាមួយរដ្ឋអំណាចបដិវត្ត ។ រដ្ឋ-អំណាចបដិវត្ត ត្រូវគ្រប់គ្រងប្រជាជនឱ្យបានល្អ លើគ្រប់ផ្នែក នយោបាយ សតិ-អារម្មណ៍ និងចាត់តាំង ។ បើធ្វើដូច្នេះ គ្មានខ្មាំងណា មកវាយយើងបានទេ ។

ជាក់ស្ដែង គឺត្រូវពង្រឹង ពង្រីកសហករណ៍ យកកម្លាំងសហករណ៍ធ្វើជាស្នូល ធ្វើឱ្យស្នូលនេះរឹងប៉ឹង សម្រាប់ស្រូបប្រជាជនថ្មី ។ ប្រជាជនថ្មីត្រូវរណបសហករណ៍ ទាំងនយោបាយ ទាំងសេដ្ឋកិច្ច ។ នេះជាទិសរបស់យើង ។ ប្រជាជនរឹង

លុះត្រាតែសហករណ៍រឹង ។ ដូច្នេះ យើងត្រូវពិនិត្យ តើសហករណ៍យើងដល់ណាហើយ ?

<u>សហករណ៍ដើរតួនាទី ២ដំណាក់ហើយ គឺ :</u>

1/- <u>តួនាទីក្នុងសង្គ្រាម</u> សហករណ៍ផ្តល់កម្លាំងគ្រប់យ៉ាង ដើម្បីវាយឈ្នះចក្រពត្តិអាមេរិក ។ សហករណ៍បានធ្វើវិភាគទានយ៉ាងខ្លាំងក្លា ។

2/- <u>តួនាទីក្រោយពេលរំដោះទាំងស្រុង</u> : សហករណ៍ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់ ពិសេសក្រុងភ្នំពេញ ហើយនៅពាយ័ព្យ គឺបាត់ដំបង ។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបង មានសមាសភាពអាក្រក់គ្រប់យ៉ាង ។ តែសហករណ៍ស្រូបយកអស់ ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំង ធ្វើការងារទៀត ។ អនុភាពសហករណ៍ខ្លាំងក្លាណាស់ ។

ដូច្នេះ ត្រូវពង្រឹង ពង្រីកសហករណ៍ថែមទៀត ។ តាមពិសោធន៍ រយៈកាលទី ១ សហករណ៍បំពេញតួនាទីខ្លួនបាន ។ រយៈកាលទី ២ ក៏វាបំពេញបាន ។ ដូច្នេះ តទៅមុខវា នឹងធ្វើបានទៀត ។

ដើម្បីការពារប្រទេសឲ្យមានប្រសិទ្ធិភាព ត្រូវដោះស្រាយជីវភាពប្រជាជនក្នុងសហករណ៍ ។ ប្រជាជនថ្មីក៏យើងខំដោះស្រាយឲ្យគេ ឲ្យគេពេញចិត្ត ពេញថ្លើម នឹងបដិវត្ត ឲ្យគេឃើញថា របបនេះ ជារបបរបស់គេ លែងឲ្យគេចង់ទៅណាទៀត ។

ដូច្នេះ បើសហករណ៍ រឹង ខ្លាំងចូលមិនចុះ វាដើរមិនបាន ធ្វើសកម្មភាពមិនបាន ចេញចូលគេដឹង សុំបាយគេដឹង ។

នៅភូមិភាគពាយ័ព្យ ជាបណ្តោះអាសន្នដោះស្រាយបាន នៅខ្វះខាតខ្លះ ។ ប្រជាជនចាស់មិនអីទេ តែប្រយ័ត្នសមាសភាពមិនល្អក្នុងប្រជាជនថ្មី វាឆ្លៀតឱកាស ។ ព្រោះពួកអានេះ បើទុកជាយើងឲ្យវាគ្រប់គ្រាន់ (២កំប៉ុង) ក៏វាមិននៅដែរ ។ យើងមិននិយាយពីពួកវាមួយក្តាប់តូចនេះទេ ។ យើងចង់និយាយពីប្រជាជនចាស់ នឹងប្រជាជនថ្មីភាគច្រើនលើសលប់ដ៏ល្អ ។ យើងត្រូវដោះស្រាយប្រជាជននេះ យកធ្វើជាបង្អែក ។

00008490



តើត្រូវដោះស្រាយយ៉ាងម៉េច ?

- ផ្លូវនៅជាប់ជើងបន្តិច តែឧបសគ្គនេះ ជាឧបសគ្គឆ្លងកាត់ទេ ។

- ប្រជាជនគេមានសង្ឃឹម ។ នៅពាយ័ព្យ លក្ខណៈភូមិសាស្ត្រអំណោយណាស់ គេឃើញច្បាស់ ។ ប្រជាជនចាស់គេរីករាយណាស់ ឯប្រជាជនថ្មីក៏រីករាយ ( ១- កងផលិតនៅខាងកើតក្រុងបាត់ដំបង ) ។ មិនដូចជានៅ ៤០៥ទេ ។ នៅកន្លែងនោះគេសង្ឃឹមតិច ( ដីតិច ទឹកតិច ស្រូវមិនល្អ ) ។ នៅឯពាយ័ព្យ គេសង្ឃឹមច្រើន គេឃើញលទ្ធភាពដែលផ្តល់ឱ្យគេ គេពេញចិត្ត ពេញថ្លើម ។

គោលការណ៍ របស់បក្ស គឺដោះស្រាយជីវភាព ។ មួយឆ្នាំ ពីរឆ្នាំទៅទៀត ជីវភាពនឹងឡើង ( សហករណ៍ប្លែក ស្រែប្រែប្រួល ទឹកប្រែប្រួល ស្បៀងលំបូរសប្បាយ ) ហើយការតែឡើងខ្ពស់ទៅទៀត ។ ឯខ្មាំងវិញ វាវិបត្តិរហូត ធ្វើខ្ញុំគេរហូត វាចេះតែធ្លាក់ទៅ ។

ដូច្នេះ មិនមែនវាវាយសំរុកយើងទេ ។ គឺយើងវាយសំរុកវា ។ ឥទ្ធិពលយើងខ្លាំងក្លាណាស់ ធ្វើគំរូឱ្យប្រជាជនថៃ នឹងប្រជាជនសកលលោក ។ បើយើងរឹតតែខ្លាំង យើងរឹតតែធ្វើគំរូ ឱ្យគេថែមទៀត ថាត្រូវតែតស៊ូទើបឈ្នះ ។

១- វិធានការដាក់សែងមួយចំនួន :

1/- តាមព្រំដែន ត្រូវឱ្យស្រុក នឹងតំបន់ ចូលរួមជាមួយភាគ ដើម្បីឱ្យស៊ាំ ឱ្យថ្នឹក ។ បើទ័ពភាគត្រូវការចល័ត ទ័ពតំបន់ នឹងស្រុកដើរតួនាទីបានហើយម្ចាស់ការ ។

2/- ផ្នែកអាវុធត្រូវប្រើរួមផ្សំសម័យថ្មីខ្លះ បុរាណខ្លះ ពិសេសប្រើចំរូងតាមព្រំដែន ។ ត្រូវមានផែនការ ១ខែដាក់ចំរូងប៉ុន្មាន ? ។ ចំរូងត្រូវប្រើគ្រប់ប្រភេទ (កំពស់ត្រឹមបាទជើង ខ្នងជើង ខ្នងជើង ឡើងទៅដល់ត្រឹមពោះ) ។

3/- ការទាក់ទងនៅព្រំប្រទល់ ស្មើឱ្យភាគក្តាប់ ឯទៀតមិនបាច់ទេ ។ ពួកវាមកទាក់ទងយើងនៅព្រំដែន មានពីរផ្នែក : អាចមានថៃ តែក៏មានអាសេរីអាដែរ ។ ដូច្នេះ កុំឱ្យទាក់ទង ។ ឱ្យទាក់ទងតែប្រចក

មួយបានហើយ ងាយស្រួលតាមដាន ។

4/- យកចិត្តទុកដាក់ពិនិត្យសហករណ៍ថែម សមាសភាពចាស់ ថ្មី ។ ឱ្យស្រុក ឃុំដឹង ហើយអប់រំសហករណ៍ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។ ខាងចាត់តាំងស្នើ ឱ្យមានជីវភាពជាប់ ។

សារុបមក ប្រជាជន និងកងទ័ព មានតួនាទីការពារប្រទេស តែប្រជាជនសហករណ៍ មានតួនាទីជាមូលដ្ឋាន ។

២- បញ្ហាសេដ្ឋកិច្ច បង្កបង្កើនផល :

ក- ទិសរបស់បក្ស គឺបង្កបង្កើនផល និងកសាងប្រទេស ។ ត្រូវចែកកម្លាំង ដែលមានដីទំនេរ ឱ្យបង្កបង្កើនផលផង ការពារប្រទេសផង ។ ម្យ៉ាងទៀត ត្រូវប្រមូលកម្លាំងទៅកន្លែងណា ដែលមានលទ្ធភាពជាងគេ គឺធ្វើតិចបានផលច្រើន ដើម្បីវាយសំរុករកទុន កសាងប្រទេសជាបន្តបន្ទាប់ ។

ដូច្នេះ ឧត្តរ និងពាយ័ព្យ ពិសេសពាយ័ព្យ ដែលមានលក្ខណៈសម្បត្តិល្អច្រើនជាងគេ ខាងភូមិសាស្ត្រដីស្រែ ( ល្អហើយសល់ច្រើន ) ត្រូវទទួលប្រជាជនថែមទៀត ។ ទី ២ មានទុនជាស្រូវ អាចចិញ្ចឹមប្រជាជនថ្មី ។ ទី ៣ មានទុនជាឧបករណ៍ផ្សេងៗ ។

យើងវាយសំរុកបង្កបង្កើនផល នៅពាយ័ព្យ ដើម្បី :

- ដោះស្រាយជីវភាពប្រជាជន(ទូទាំងប្រទេស) ។
- រកទុនថ្មី ទិញឧបករណ៍ កសាងប្រទេស និងបង្កបង្កើនផលកសិកម្ម និងឧស្សាហកម្ម

បើយកកម្លាំងទៅកន្លែងផ្សេង ដែលមានលទ្ធភាពតិច នោះយើងខាតទាំងប្ដី ទាំងស្គរ ។ មាគ៌ាប្រយុទ្ធរបស់យើងមិនត្រូវ ។ ដូច្នេះ ត្រូវប្រយុទ្ធត្រង់ណាដែលមានប្រសិទ្ធិភាព ព្រោះយើងអនុវត្ត នយោបាយខ្លួនឧបត្ថម្ភខ្លួន ។ យើងត្រូវរកទុនដោយខ្លួនយើង ។

៣- ការរៀបចំកម្លាំងមនុស្ស :

ភូមិភាគពាយ័ព្យមានលក្ខណៈសម្បត្តិងាយស្រួល នឹងលំបាកដូចតទៅ :

1/- លក្ខណៈសម្បត្តិងាយស្រួល :

- ដីល្អជាទូទៅ មិនចាំបាច់ប្រើជីរក៏ល្អ ។
- វាលរាបល្វឹងល្វើយ គ្មានភ្នំ ងាយស្រួលឱ្យយើងចាត់ចែងកម្លាំងភ្ជួររាស់ នឹងប្រើប្រាស់ទឹក ។
- មានកម្លាំងមនុស្សដែរ ។ យើងបន្ថែមទៀត រឹតតែល្អ ។ កម្លាំងគោក៏មានពិសោធន៍បង្កបង្កើនផល ។
- មានឧបករណ៍ម៉ាស៊ីនខ្លះ ។

2/- ចំណុចខ្វះខាត ឬត្រូវចាប់អារម្មណ៍ :

- មិនទាន់ម្ចាស់ការលើទឹក ។
- កម្លាំងមនុស្សមិនគ្រប់ ។ ត្រូវបន្ថែមកម្លាំងពលកម្ម ៣ ឬ ៤ដងទៀត ក៏មិនគ្រប់ ។ កម្លាំង ១លាននាក់បច្ចុប្បន្ន ធ្វើមិនបាន ៥០ភាគរយទេ ។ ត្រូវថែម ៤ ឬ ៥ដងទៀត ។ យើងយកមកល្មមសិន ព្រោះត្រូវទុកលើកផ្នែកផ្សេងទៀត ។
- បើខ្វះកម្លាំងមនុស្ស ត្រូវដោះស្រាយដោយកម្លាំងម៉ាស៊ីន ។

សារុបមក ត្រូវដោះស្រាយ :

- ទី ១ បញ្ហាទឹក ជាទិសសំខាន់ ភាគ នឹងតំបន់ត្រូវមានផែនការដោះស្រាយបញ្ហាទាំងអស់ ត្រូវមានក្រសួងវា ។
- ទី ២ កម្លាំងពលកម្ម គឺកម្លាំងមនុស្ស នឹងឧបករណ៍ម៉ាស៊ីន ។

គ- បញ្ហាម៉ាស៊ីន : ត្រូវប្រមូលម៉ាស៊ីន ទាំងអស់ ពិសេសត្រាក់ទ័រ ហើយភាគក្តាប់ ។

- ត្រូវថែរក្សាវា មានចាត់តាំងគ្រប់គ្រងរោងជាងជួសជុល រោងចក្រគ្រឿងបន្ត ។ សំរាប់ភាគ គឺរៀបចំរោងជាងជួសជុល ឬការដ្ឋាន

00008493



គ្រឿងយន្តកសិកម្ម របស់ភូមិភាគ ។ ទៅអនាគត រោងជាងនេះ នឹងប្រែក្លាយទៅជារោងចក្រ ។ ខ- រោងជាងជួសជុលត្រាក់ទ័រ នឹងទៅជារោងចក្រតម្លើងត្រាក់ទ័រ ។

- ស្នើរៀបចំស្ថានីយ៍ពិសោធកសិកម្មមួយ ។ មិនចាំបាច់ធំទេ ធ្វើតូចល្មមសិន ។ ត្រូវគិតពីពូជ ពីវិធីសម្លាប់សត្វល្អិត ពីជី ។ល។ យើងធ្វើជាបណ្តើរៗ ។

៣- បញ្ហាផ្សេងៗ :

ក- ក្រុមផលិត : ចាំបាច់តាំងឈ្លបបង្គូរ ។ យើងត្រូវចំរើនកម្លាំងថ្មី កុំឱ្យនៅផ្តុំ ។ សំខាន់យកចិត្តទុកដាក់ខាងនយោបាយ ហ្វឹកហ្វឺនអប់រំគេ កុំឱ្យខ្មាំងធ្វើសកម្មភាព នានា ។ ដូច្នោះកណ្តាលទៅទៀត អាចពង្រីកបាន ។

ខ- បញ្ហាក្រុង : ត្រូវថែទាំវា ផ្ទះឈើតូចតាចស្នើឱ្យរុះចុះ តែត្រូវចាត់តាំងកម្លាំងទើររុះ ។ ក្នុងក្រុងស្នើដាំដំណាំយុទ្ធសាស្ត្រផង ដូចជាដូង ។ កន្លែងខ្លះ ស្នើកុំដាំចេក នាំឱ្យខូចសោភ័ណភាព ។

គ- បញ្ហាពេទ្យ : ស្នើឱ្យរៀបចំមន្ទីរពេទ្យ និងជួរពេទ្យជាបណ្តើរៗ ៕